**ព្រឹត្តិប័ត្រសារព័ត៌មាន** **ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៦**

# ធនាគារ មេយប៊ែង ខេមបូឌា និង SUNWAY MEDICAL CENTRE ក្នុងតំបន់ Sunway City ពង្រីកអត្ថប្រយោជន៍ពិសេសជូនអតិថិជន ជាមួយកញ្ចប់ពិនិត្យសុខភាពដោយឥតគិតថ្លៃនៅប្រទេសម៉ាឡេស៊ី។

*កិច្ចសហប្រតិបត្តិការនេះផ្តល់ជូនអតិថិជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នូវអត្ថប្រយោជន៍ពិសេសៗលើសេវាថែទាំសុខភាព ការធ្វើដំណើរ និងការរស់នៅក្នុងប្រទេសម៉ាឡេស៊ី ហើយអ្វីដែលកាន់តែពិសេសនោះ គឺយើងមានបន្ថែមនូវយុទ្ធនាការពិនិត្យសុខភាពដោយឥតគិតថ្លៃទៀតផង។*

**ភ្នំពេញថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៦ –** ធនាគារ មេយប៊ែង និង Sunway Medical Centre ដែលមានទីតាំងនៅក្នុងតំបន់ Sunway City ទីក្រុងកូឡាឡាំពួរ (SMC) បានប្រកាសជាផ្លូវការ ពីកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រ ក្នុងគោលបំណងពង្រីកឱកាសដល់ប្រជាជនកម្ពុជា ឱ្យទទួលបាននូវអត្ថប្រយោជន៍ពិសេសៗជាច្រើន ទាក់ទងនឹងសេវាកម្មថែទាំសុខភាព ការធ្វើដំណើរ និងការរស់នៅបែបទំនើបនៅក្នុងប្រទេសម៉ាឡេស៊ី។

ការប្រកាសជាផ្លូវការនេះ ឆ្លុះបញ្ចាំងពីកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងស្ថាប័នទាំងពីរ តាមរយៈការផ្សារភ្ជាប់បណ្តាញតំបន់អាស៊ាន និងប្រព័ន្ធអេកូឡូស៊ីអតិថិជនរបស់ធនាគារ មេយប៊ែង ជាមួយអ្នកជំនាញផ្នែកសុខាភិបាល ក៏ដូចជាសេវាកម្មថែទាំអ្នកជំងឺប្រកបដោយការយកចិត្តទុកដាក់ខ្ពស់របស់ SMC។

ចំណុចពិសេសនៃព្រឹត្តិការណ៍នេះ គឺយុទ្ធនាការដែលកំពុងដំណើរការ «Beyond Wealth, Into Wellbeing» ។ តាមរយៈយុទ្ធនាការនេះ អតិថិជនដែលជាម្ចាស់ប័ណ្ណមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងទទួលបានការពិនិត្យសុខភាពដោយឥតគិតថ្លៃនៅ SMC។

បន្ថែមពីលើការពិនិត្យសុខភាពដោយឥតគិតថ្លៃ ម្ចាស់ប័ណ្ណធនាគារ មេយប៊ែង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក៏នឹងទទួលបានអត្ថប្រយោជន៍ថែទាំសុខភាពពិសេសនៅ SMC រួមទាំងការបញ្ចុះតម្លៃ ២០% លើកញ្ចប់ពិនិត្យសុខភាពដែលបានជ្រើសរើសផងដែរ។

លើសពីនេះ កិច្ចសហប្រតិបត្តិការនេះក៏រួមបញ្ចូលទាំងអត្ថប្រយោជន៍ពិសេសសម្រាប់ការធ្វើដំណើរ បដិសណ្ឋារកិច្ច និងការគាំទ្រអ្នកជំងឺ ដូចជា៖ ការស្នាក់នៅដោយឥតគិតថ្លៃចំនួន ១យប់ សេវាដឹកជញ្ជូនទៅ មកព្រលានយន្តហោះដោយឥតគិតថ្លៃ សេវាអ្នកបកប្រែភាសា ការបញ្ចុះតម្លៃពិសេសនៅសណ្ឋាគារ Sunway Sanctuary ព្រមទាំងសេវាកម្មផ្សេងៗទៀត ដែលត្រូវបានរៀបចំឡើងដើម្បីផ្តល់ភាពងាយស្រួល និងផាសុកភាពកាន់តែខ្លាំង សម្រាប់អតិថិជនដែលធ្វើដំណើរទៅកាន់ប្រទេសម៉ាឡេស៊ី ដើម្បីទទួលសេវាថែទាំសុខភាព និងសុខុមាលភាព។

ក្រៅពីអត្ថប្រយោជន៍ផ្នែកសុខភាព ការផ្តល់ជូននេះក៏រួមបញ្ចូលផងដែរនូវឯកសិទ្ធិពិសេសៗលើការធ្វើដំណើរ និងរបៀបរស់នៅក្នុងតំបន់ តាមរយៈប័ណ្ណធនាគារ មេយប៊ែង ដែលរួមមានការបញ្ចុះតម្លៃរហូតដល់ ១៥% លើថ្លៃសំបុត្រយន្តហោះជាមួយក្រុមហ៊ុនអាកាសចរណ៍ Malaysia Airlines។

តាមរយៈកិច្ចសហការនេះ យើងបានបង្កើតនូវបទពិសោធន៍ថែទាំសុខភាពឆ្លងប្រទេសដ៏ពេញលេញមួយ ដែលគ្របដណ្តប់លើគ្រប់តម្រូវការ ចាប់តាំងពីការរៀបចំការធ្វើដំណើរ សេវាថែទាំ និងការពិនិត្យសុខភាព ការស្នាក់នៅ រហូតដល់ការផ្តល់ការគាំទ្រដល់អ្នកជំងឺ។

**លោក រ័ត្ន សោភ័ណ នាយកប្រតិបត្តិ និងជានាយកប្រចាំប្រទេសនៃធនាគារ មេយប៊ែង** បានមានប្រសាសន៍ថា៖ «កិច្ចសហប្រតិបត្តិការនេះបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់ធនាគារ មេយប៊ែង ក្នុងការផ្តល់ជូននូវបទពិសោធន៍ថ្មីៗដល់អតិថិជន ដែលលើសពីការផ្តល់សេវាហិរញ្ញវត្ថុធម្មតា ដោយផ្តោតលើរបៀបរស់នៅ សុខុមាលភាព និងការតភ្ជាប់ទំនាក់ទំនងក្នុងតំបន់។»

«សេវាកម្មធនាគារនាពេលបច្ចុប្បន្ន មិនមែនមានត្រឹមតែការផ្តល់ជូនផលិតផលហិរញ្ញវត្ថុប៉ុណ្ណោះ ផ្ទុយទៅវិញ វាត្រូវបានឆ្លុះបញ្ចាំងកាន់តែខ្លាំងឡើងតាមរយៈលទ្ធភាពទទួលបាន ទំនុកចិត្ត និងគុណតម្លៃដែលយើងអាចបង្កើតជូនអតិថិជនក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគាត់។

តាមរយៈកិច្ចសហប្រតិបត្តិការជាមួយ Sunway Medical Centre យើងមានគោលបំណងភ្ជាប់ទំនាក់ទំនងអតិថិជនកម្ពុជារបស់យើង ទៅកាន់សេវាថែទាំសុខភាពដែលមានទំនុកចិត្តខ្ពស់ ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍លើការធ្វើដំណើរ និងរបៀបរស់នៅឆ្លងប្រទេសផងដែរ ដែលបានបង្ហាញឱ្យឃើញពីឆន្ទៈរបស់ធនាគារ មេយប៊ែង ក្នុងការផ្តល់ជូននូវបទពិសោធន៍កាន់តែប្រសើរ និងមានន័យសម្រាប់អតិថិជនរបស់យើងនៅទូទាំងតំបន់អាស៊ាន។ តាមរយៈយុទ្ធនាការ «Beyond Wealth, Into Wellbeing» យើងកំពុងពង្រឹងបន្ថែមលើសេវាកម្ម Premier ដើម្បីគាំទ្រទាំងសុខុមាលភាពហិរញ្ញវត្ថុ និងសុខភាពផ្ទាល់ខ្លួនរបស់អតិថិជនរបស់យើងឱ្យកាន់តែប្រសើរឡើង។»

**លោកវេជ្ជបណ្ឌិត Khoo Chow Huat នាយកគ្រប់គ្រង (ផ្នែកប្រតិបត្តិការមន្ទីរពេទ្យ និងសេវាថែទាំសុខភាព) នៃ Sunway Healthcare Group** បានមានប្រសាសន៍ថា៖ «កិច្ចសហប្រតិបត្តិការនេះនឹងជួយបង្កើតឱ្យមានការតភ្ជាប់ និងបង្កើនទំនុកចិត្តកាន់តែខ្លាំង សម្រាប់ប្រជាជនកម្ពុជា ដែលស្វែងរក សេវាព្យាបាល និងថែទាំសុខភាពដែលមានស្តង់ដារនៅប្រទេសម៉ាឡេស៊ី។»

លោកបានមានប្រសាសន៍ថា៖ «ដំណើរថែទាំសុខភាព គឺត្រូវចាប់ផ្តើមចេញពីទំនុកចិត្តជាចម្បង ពោលគឺទំនុកចិត្តលើសមត្ថភាពគ្រូពេទ្យ បរិយាកាសនៃការថែទាំ ក៏ដូចជាការយកចិត្តទុកដាក់ដែលផ្តល់ជូនដល់អ្នកជំងឺ និងក្រុមគ្រួសាររបស់ពួកគេ។ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយធនាគារ មេយប៊ែង ខេមបូឌា Sunway Medical Centre យើងកំពុងធ្វើឱ្យដំណើរការនៃការស្វែងរកសេវាពិនិត្យសុខភាព សុខុមាលភាព និងការព្យាបាលផ្សេងៗនៅប្រទេសម៉ាឡេស៊ី កាន់តែមានភាពងាយស្រួល និងទទួលបានការគាំទ្រយ៉ាងពេញលេញសម្រាប់ប្រជាជនកម្ពុជា។»

លោកបានបន្ថែមទៀតថា៖ «នៅ Sunway Medical Centre យើងផ្តល់ជូននូវឧត្តមភាពផ្នែកវេជ្ជសាស្ត្រ បដិសណ្ឋារកិច្ចដ៏ល្អ និងការយកចិត្តទុកដាក់ខ្ពស់បំផុតលើអ្នកជំងឺ នៅក្នុងប្រព័ន្ធថែទាំសុខភាពដ៏ទូលំទូលាយរបស់យើង។ ការចាប់ដៃគ្នាជាមួយធនាគារ មេយប៊ែង គឺយើងមិនមែនគ្រាន់តែផ្តល់ការព្យាបាលប៉ុណ្ណោះទេ ប៉ុន្តែយើងកំពុងបង្កើតនូវបទពិសោធន៍ថ្មីមួយដែលផ្តល់នូវភាពងាយស្រួល ផាសុកភាព និងភាពកក់ក្តៅ ចាប់តាំងពីពេលចាប់ផ្តើមធ្វើដំណើរ រហូតដល់ការទទួលបានសេវាថែទាំសុខភាពយ៉ាងពេញលេញ។»

កិច្ចសហប្រតិបត្តិការនេះ គឺជាសមិទ្ធផលដ៏សំខាន់មួយសម្រាប់ធនាគារ មេយប៊ែង និង SMC ក្នុងការបង្កើតនូវវេទិកាមួយដ៏ទូលំទូលាយ ដើម្បីពង្រឹងការចូលរួមលើវិស័យថែទាំសុខភាព បង្កើនអត្ថប្រយោជន៍ជូនដល់អតិថិជន និងជំរុញគំនិតផ្តួចផ្តើមថ្មីៗសម្រាប់របៀបរស់នៅនាពេលអនាគត ដែលជាគ្រឹះដ៏រឹងមាំសម្រាប់ការពង្រឹងទំនាក់ទំនងជិតស្និទ្ធរវាងកម្ពុជា និងម៉ាឡេស៊ីផងដែរ។